Better Factories Cambodia

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

# ឯកសារយុទ្ធសាស្ត្រ ២០១៩-២០២២

ភាពជាដៃគូដើម្បីលើកកម្ពស់ភាពអនុលោមតាមច្បាប់នាពេលអនាគត




International Labour Organization

International Finance Corporation
WORLD BANK GROUP

ចាប់តាំងពីឆ្នាំ ២០០១ មក រោងចក្រកាន់តែប្រសើរនៅកម្ពុជាបានចូលរួម សហការជាមួយនឹងកម្មករ និយោជិត និយោជក និងរដ្ឋាភិបាល ដើម្បីកែលម្អ លក្ខខណ្ឌការងារ និងបង្កើតភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរ សំលៀកបំពាក់។

កាលពីដំបូង គម្រោងនេះត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងកិច្ច ព្រមព្រៀងពាណិជ្ជកម្មបែបថ្មីរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋអាមេរិក ដែលអាចទទួលបានចំណែកទីផ្សារនាំចេញ ដោយត្រូវលើកកម្ពស់លក្ខខណ្ឌការងារ ក្នុងវិស័យកាត់ដេរ។ បន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះផុតសុពលភាពកាលពី ឆ្នាំ ២០០៤ រដ្ឋាភិបាលកម្ពុជា រួមនឹងសហជីព និងនិយោជក បានស្នើអង្គការអន្តរ ជាតិខាងការងារ (ILO) បន្តអនុវត្តកម្មវិធីនេះទៀត។

ក្នុងនាមជាកម្មវិធីដែលដំណើរការយូរជាងគេកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា គឺជាកម្លាំងចលករ ដែលស្ថិតនៅពីក្រោយការបង្កើតកម្មវិធីការងារកាន់តែប្រសើរ (Better Work) និងបានលើកទឹកចិត្តឱ្យមានការបង្កើតកម្មវិធីបែបនេះក្នុងប្រទេសចំនួនប្រាំបួនផ្សេងទៀត។ សមាសភាគសំខាន់ៗនៃវិធីសាស្ត្រដែលកម្មវិធីនេះប្រើប្រាស់មានប្រភពចេញពីប្រទេសកម្ពុជា៖ ចេញពីការ ជំរុញឱ្យមានកិច្ចសន្ទនាសង្គមតាមរយៈគណៈកម្មការទ្វេភាគីដែលមានសមាសភាពជាកម្មករ និយោជិត និងអ្នកគ្រប់គ្រងរហូតដល់ការរៀបចំសេវាផ្តល់ប្រឹក្សាទៅតាមតម្រូវការជាក់លាក់របស់រោងចក្រក្នុងគោលបំណងជួយរោងចក្រទាំងនោះក្នុងការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងសិទ្ធិការងារ ឬការប្រើប្រាស់របាយការណ៍សាធារណៈដើម្បីជំរុញឱ្យមានការកែលម្អលក្ខខណ្ឌការងារក្នុងរោងចក្រ និងបរិយាកាសនៅកន្លែងធ្វើការក្នុងឧស្សាហកម្មទាំងមូល។

ជាមួយនឹងវិសាលភាពគ្របដណ្តប់លើរោងចក្រចំនួន ៥៥០ និងកម្មករចំនួន ៦៣០.០០០ នាក់ កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជានឹងបន្តពង្រីកបន្ថែមពីលើជោគជ័យដែលសម្រេចបាននៅតាមរោងចក្រ ព្រមទាំងពង្រឹងការសហការជាមួយនឹងដៃគូរបស់ខ្លួនឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ក៏ដូចជា ចាប់ផ្តើមអនុវត្តដំណើរការមួយដែលនឹងធ្វើការកំណត់ពីអ្វីដែលជារឿងចាំបាច់ដើម្បីបង្កើតវប្បធម៌អនុលោមតាមច្បាប់ក្នុងវិស័យនេះ។

តាមរយៈការសហការជាមួយនឹងដៃគូជាតិ និងអន្តរជាតិដើម្បីដាក់ចេញនូវចក្ខុវិស័យថ្មីសម្រាប់វិស័យនេះ និងសម្រេចឱ្យបាននូវចក្ខុវិស័យនេះរោងចក្រកាន់តែប្រសើរនៅកម្ពុជានឹងបន្តលើកកម្ពស់ការងារសមរម្យនិងមានសុវត្ថិភាពដល់កម្មកររាប់សែននាក់ ជាពិសេសស្ត្រី។កម្មវិធីនេះនឹងសហការជាមួយនឹងដៃគូសំខាន់ៗ ព្រមទាំងតួអង្គពាក់ព័ន្ធនានាក្នុងឧស្សាហកម្មនេះដើម្បីជួយឱ្យកម្មករអភិវឌ្ឍជំនាញថ្មីៗ ហើយក្នុងពេលជាមួយគ្នាជួយឱ្យការធ្វើជំនួញក្នុងឧស្សាហកម្មនេះនាំមកនូវប្រាក់ចំណេញកាន់តែខ្ពស់ ជាងមុន និងជួយឱ្យប្រជាពលរដ្ឋទូទាំងប្រទេសចាកផុតពីភាពក្រីក្រ។

នាពេលបច្ចុប្បន្នេះ កម្មវិធីនេះបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ដំណាក់កាលថ្មីរបស់ខ្លួនដែលជាដំណាក់កាលយុទ្ធសាស្ត្រពីឆ្នាំ ២០១៩-២០២២។ ដំណាក់កាលដែលនឹងមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត លើការបង្កើតវប្បធម៌អនុលោមតាមច្បាប់ក្នុងឧស្សាហកម្មមួយដែលធានាបាននូវភាពត្រឹមត្រូវ និងយុត្តិធម៌ទាមទារឱ្យមានការសហការយ៉ាងជិតស្និទរវាងដៃគូនានាក្នុងប្រទេសក៏ដូចជាជាមួយនឹងអ្នកដែលមានតួនាទីពាក់ព័ន្ធក្នុងឧស្សាហកម្មនេះនៅកម្រិតអន្តរជាតិ។

ឯកសារនេះដាក់ចេញទិសដៅជាយុទ្ធសាស្ត្ររយៈពេលវែងក្នុងការឈានទៅបង្កើត ឧស្សាហកម្មមួយដែលលក្ខខណ្ឌការងារល្អប្រសើរ ប្រកបដោយស្ថិរភាពក្លាយជាស្តង់ដារដោយមាន ការគាំទ្រពីតួអង្គពាក់ព័ន្ធនិងស្ថាប័ននានាដែលធ្វើការងារពាក់ព័ន្ធនឹងឧស្សាហកម្មនេះ។ ក្រោមក្របខ័ណ្ឌនៃទិសដៅយុទ្ធសាស្ត្ររួមនេះ ឯកសារនេះនឹងបង្ហាញពីអាទិភាពសម្រាប់ដំណាក់កាលយុទ្ធសាស្ត្រថ្មីរបស់ BFC និងពីដំណើរការដែលជួយបំប្លែងទិសដៅជាយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ឧស្សាហកម្មនេះជាសកម្មភាពលទ្ធផល និងសូចនាករដែលមានភាពច្បាស់លាស់និងអាចវាស់វែងបាន។

ឯកសារនេះគឺជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់យ៉ាងស៊ីជម្រៅជាមួយនឹងតួអង្គពាក់ព័ន្ធ និងដៃគូសំខាន់ៗរបស់ BFC ព្រមទាំងការពិគ្រោះយោបល់ដែលធ្វើឡើងក្នុងលក្ខណៈឯករាជ្យជាមួយនឹងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សហជីពកម្ពុជា ក្រុមរោងចក្រអ្នកគ្រប់គ្រងរោងចក្រ ដៃគូបញ្ជាទិញអន្តរជាតិ អង្គការសហប្រជាជាតិនៅកម្ពុជា តំណាង ILO និង BFC តួអង្គ

ពាក់ព័ន្ធដទៃទៀតដែលមកពីសហគមន៍អន្តរជាតិនៅកម្ពុជា។

## ការផ្លាស់ប្តូរជាវិជ្ជមាន និងលទ្ធផលសម្រេចបានរបស់ BFC នៅក្នុងឧស្សាហកម្មនេះ

ក្នុងអំឡុងដំណើរការពិគ្រោះយោបល់ដៃគូនានាបានគូសបញ្ជាក់សាជាថ្មីពីលទ្ធផលរយៈពេលវែងដែលកម្មវិធីនេះផ្តល់ដល់ឧស្សាហកម្មកាត់ដេរនៅកម្ពុជា និងកម្មករដែលធ្វើការងារក្នុងវិស័យនេះ តាមរយៈភាពជាដៃគូជាមួយនឹងតួអង្គពាក់ព័ន្ធនានា។ លទ្ធផលរយៈពេលវែងទាំងនេះរួមមាន៖

- ទំនុកចិត្ត និងការប្តេជ្ញាចិត្តរបស់អ្នកបញ្ជាទិញ និងក្រុមហ៊ុនអ្នកបញ្ជាទិញអន្តរជាតិធំៗមកលើកម្មវិធីនេះ និងលើវិស័យកាត់ដេររបស់កម្ពុជា
- ការកែលម្អគួរឱ្យកត់សម្គាល់នូវលក្ខខណ្ឌការងារក្នុងឧស្សាហកម្មនេះក្នុងទសវត្សរ៍ចុងក្រោយ ដោយBFC បំពេញតួនាទីយ៉ាងសំខាន់ ហើយក៏ជាកត្តាដែលរួមចំណែកនាំឱ្យមានការកែលម្អទាំងនេះផងដែរ ព្រមទាំងលទ្ធផលជាវិជ្ជមានមកលើកេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជាលើឆាកអន្តរជាតិក្នុងនាមជាប្រភពនៃការបញ្ជាទិញផលិតផលសម្លៀកបំពាក់
- BFC គឺជាតួអង្គដែលអព្យាក្រឹតឯករាជ្យមានការគ្រប់គ្រងបានល្អឆ្លើយតបចំពោះតម្រូវការផ្សេងៗ និងបំពេញតួនាទីរយៈពេលវែងជាមួយនឹងឧស្សាហកម្ម និងតួអង្គពាក់ព័ន្ធដទៃទៀតក្នុងនាមជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន
- ភាពជាដៃគូសហការប្រកបដោយប្រសិទ្ធភាពរបស់ BFC ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និយោជក និងសហជីពនៅកម្ពុជា
- ការកែលម្អទំនាក់ទំនងវិជ្ជាជីវៈតាមរយៈការសហការដែលមានលក្ខណៈស្ថាបនា និងប្រកបដោយការទទួលខុសត្រូវខ្ពស់ជាងមុនជាមួយនឹងសហជីពនៅតាមរោងចក្រជុំវិញបញ្ហាដែលកើតមាននៅកន្លែងធ្វើការ និងការសហការជាមួយនឹងសហជីពទាំងនេះក្នុងយន្តការពិគ្រោះយោបល់ត្រីភាគី
- តួនាទីរបស់ BFC ក្នុងការសហការជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីអធិការកិច្ចការងារ ដើម្បីជួយកសាងសមត្ថភាពជំនាញ ការប្តេជ្ញាចិត្ត និងសុចរិតភាពរបស់មន្ត្រី អធិការងារ ក្នុងការចុះធ្វើអធិការកិច្ចធានាឱ្យមានភាពអនុលោមតាមច្បាប់នៅតាមកន្លែងធ្វើការ
- ជាលទ្ធផលនៃការសហការរវាង BFC និងក្រសួងពាណិជ្ជកម្មនាំឲ្យមានការទទួលស្គាល់ពីដៃគូអំពីសារៈសំខាន់នៃបទដ្ឋានការងារក្នុងគោលនយោបាយពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាល
- ការរួមចំណែកដ៏សំខាន់របស់ BFC ក្នុងការរៀបចំយុទ្ធសាស្ត្រសម្រាប់អនាគតរបស់វិស័យកាត់ដេរដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតួនាទីដែលកម្មវិធីនេះអាចមាននាពេលអនាគត ក្នុងនាមជាអ្នកពិនិត្យតាមដានការអនុវត្តសកម្មភាពផ្សេងៗនៃយុទ្ធសាស្ត្រនេះ។

តួអង្គពាក់ព័ន្ធនានាក៏ទទួលស្គាល់ផងដែរថាការងាររបស់ BFC នៅមិនទាន់ចប់នៅឡើយទេ។ ដោយប្រើប្រាស់នូវយុទ្ធសាស្តដែលបានអនុវត្តរួចទៅហើយពីលើកមុនដៃគូនានាចាំបាច់ត្រូវសម្លឹងទៅមុខដើម្បីស្វែករកទិសដៅដែលមានរយៈពេលវែងហើយអាចធានាថា លទ្ធផលរយៈពេលមធ្យមលទ្ធផលរយៈពេលវែង និងការអភិវឌ្ឍន៍សមត្ថភាពដែលទទួលបានការគាំទ្រកន្លងមកពី BFC នឹងនៅបន្តមាននិរន្តរភាពឋិតថេរទៅមុខទៀត។ ដើម្បីសម្រេចគោលបំណងនេះ គឺទាមទារឲ្យមានការសហការរួមគ្នាផ្តោតដោយលើការកសាងវប្បធម៌អនុវត្តន៍ការងារឲ្យបានល្អ និងធានាបាននូវនិរន្តរភាពនៃការអនុវត្តតាមច្បាប់ដែលជួយឲ្យឧស្សាហកម្មនេះក្លាយជាឧស្សាហកម្មមួយដែលរោងចក្រអាចគោរពតាមច្បាប់ស្តីពីការងារដោយខ្លួនឯងដោយលែងចាំបាច់មានការចុះត្រួតពិនិត្យលក្ខខណ្ឌការងារ ឬវាយតម្លៃអ្វីទៀតពោលគឺជាវិស័យមួយដែលរោងចក្រមានលក្ខខណ្ឌការងារល្អហើយក្លាយជា

បទដ្ឋានទូទៅក្នុងការរៀបចំផែនការធុរកិច្ច និងភាពប្រកួតប្រជែងរបស់ឧស្សាហកម្មដែលកម្មករលែងចាំបាច់ត្រូវបារម្ភថាសិទ្ធិរបស់ពួកគេអាចមិនត្រូវបានគេគោរព សហជីពមិនចាំបាច់ភ័យខ្លាចថាពួកគេអាចត្រូវបានគេបណ្តេញចេញពីការងារដោយសារតែសកម្មភាពសហជីព ហើយអ្នកគ្រប់គ្រងរោងចក្រក៏មិនចាំបាច់ភ័យខ្លាចការធ្វើកូដកម្ម រីឯក្រុមហ៊ុនអ្នកបញ្ជាទិញក៏មិនចាំបាច់មានការព្រួយបារម្ភពីហានិភ័យពាក់ព័ន្ធនឹងការរំលោភបំពាន ការឈប់ធ្វើការក្នុងពេលកូដកម្ម និងដែលតួអង្គពាក់ព័ន្ធ នានានៅថ្នាក់ជាតិលែងចាំបាច់ព្រួយបារម្ភពីឧបទ្ទវហេតុថ្មីៗដែលអាចកើតមានឡើងនៅពេល ណាមួយ។

បើទោះបីជានៅមានការងារជាច្រើនចាំបាច់ត្រូវធ្វើយ៉ាងណាក៏ដោយ ការនាំមកនូវកាផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យនេះ អាចធ្វើទៅបាននៅពេលដែលអ្នកគ្រប់គ្រងរោងចក្រកម្មករ និងតំណាងរបស់ពួកគេយល់ពីច្បាប់ស្តីពីការងារ និងនៅពេលដែលមានយន្តនៃកិច្ចសន្ទនាសង្គមប្រកបដោយ ប្រសិទ្ធភាពនៅកម្រិតរោងចក្រដែលផ្តល់លទ្ធភាពឲ្យកម្មករ និងអ្នកគ្រប់គ្រងអាចជួបប្រជុំគ្នាជា ទៀងទាត់ដើម្បីពិភាក្សាពីវឌ្ឍនភាពនានា និងស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលកើតមាននៅកន្លែងធ្វើការ។

ការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យនេះអាចធ្វើទៅបានប្រសិនបើរដ្ឋាភិបាលដាក់ចេញនូវចក្ខុវិស័យជាយុទ្ធសាស្ត្រដោយមានការគាំទ្រពីតួអង្គនានាក្នុងឧស្សាហកម្មដើម្បីធ្វើឲ្យឧស្សាហកម្មកាត់ដេររបស់ប្រទេសនេះមានភាពប្រកួតប្រជែងផលិតភាព និងផ្តល់នូវភាពយុត្តិធម៌ដែលក្នុងនោះលក្ខខណ្ឌការងារល្អប្រសើរ និងកិច្ចសន្ទនាសង្គមក្លាយជាសមាសភាគស្នូលដ៏សំខាន់មួយ។

ការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យនេះ អាចធ្វើទៅបានប្រសិនបើរដ្ឋាភិបាលដាក់ចេញនូវចក្ខុវិស័យជាយុទ្ធសាស្ត្រដោយមានការគាំទ្រពីតួអង្គនានាក្នុងឧស្សាហកម្មដើម្បីធ្វើឲ្យឧស្សាហកម្មកាត់ដេររបស់ប្រទេសនេះមានភាពប្រកួតប្រជែងផលិតភាព និងផ្តល់នូវភាពយុត្តិធម៌ ដែលក្នុងនោះលក្ខខណ្ឌការងារល្អប្រសើរ និង កិច្ចសន្ទនាសង្គមក្លាយជាសមាសភាគស្នូលដ៏ សំខាន់មួយ។

ការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យនេះអាចធ្វើទៅបានប្រសិនបើមានអភិបាលកិច្ចរឹងមាំលើទីផ្សារការងារ និងមានការយល់ច្បាស់ពីច្បាប់ស្តីពីការងារដែលត្រូវបានឲ្យអនុវត្តការគោរពតាមបទដ្ឋានការងារអន្តរជាតិ និងមានការគាំទ្រពីប្រព័ន្ធសន្ទនាសង្គម ប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធអធិការកិច្ច និងការអនុវត្តច្បាប់ដែលមានភាពចាស់ទុំ។

ការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យមួយអាចធ្វើទៅបានប្រសិនបើមានប្រព័ន្ធគ្រប់គ្រងបញ្ហាសុខភាព និងសុវត្ថិភាពការងារ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សដែលរឹងមាំសម្រាប់គាំទ្រដល់ការអនុវត្តបទដ្ឋានការងាអន្តរជាតិ និងលើកកម្ពស់ការអនុវត្តល្អៗ ហើយអ្នកបញ្ជាទិញ និងអ្នកទិញនឹងជួយគាំទ្រឲ្យរោងចក្រធ្វើការផ្លាស់ប្តូរជាវិជ្ជមាន និងផ្តល់រង្វាន់ដល់រោងចក្រដែលបំពេញការងារបានល្អតាមរយៈការដាក់ការបញ្ជាទិញជាប់ជាបន្តបន្ទាប់ និងផ្តល់តម្លៃសមរម្យដល់រោងចក្រទាំងនោះ។

ការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យមួយអាចធ្វើទៅបាននៅពេលដែលរាល់តួអង្គពាក់ព័ន្ធទាំងអស់ដូចជា រដ្ឋាភិបាល សហជីព រោងចក្រ និយោជក និងក្រុមហ៊ុនអ្នកបញ្ជាទិញត្រូវទទួលខុសត្រូវទាំងស្រុង និងធ្វើការសហការគ្នាដោយបើកចំហប្រកបដោយតម្លាភាព និងគណនេយ្យភាពដោយប្រើប្រាស់នូវភស្តុតាងដែលបានមកពីការសិក្សាស្រាវជ្រាវដើម្បីរៀបចំ គោលនយោបាយ និងបង្ហាញទិន្នន័យប្រកបដោយតម្លាភាពដែលអាចបញ្ជាក់ និងផ្ទៀងផ្ទាត់បាន អំពីស្ថានភាពរបស់ឧស្សាហកម្មទាំងមូល។

ដើម្បីឲ្យអ្វីដែលបានរៀបរាប់ខាងលើក្លាយទៅជាការពិតសម្រាប់ប្រទេសកម្ពុជា គឺទាមទារឲ្យមាន

ការខិតខំធ្វើការងារបន្ថែមទៀតនិងត្រូវចាត់ទុកអ្វីដែលរៀបរាប់ទាំងនេះ ថាជាគោលដៅដែលត្រូវសម្រេចឲ្យបានក្នុងរយៈពេលវែង។ ភាគីពាក់ព័ន្ធនានាបានស្នើឲ្យ BFC ពន្លឿនដំណើរការនេះ ដូច្នេះសម្រាប់ផែនការយុទ្ធសាស្ត្របន្ទាប់ គឺដៃគូពាក់ព័ន្ធនានាកាន់តែអាចកំណត់បានយ៉ាងច្បាស់ពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើដើម្បីឱ្យឧស្សាហកម្មនេះក្លាយជាឧស្សាហកម្មដែលផ្តល់នូវភាពយុត្តិធម៌ និងធានាបាននូវភាពអនុលោមតាមច្បាប់ប្រកបដោយនិរន្តរភាពដែលអាចកំណត់ពីភាពជោគជ័យ និងភាពជាដៃគូដែលចាំបាច់ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងឧស្សាហកម្មនេះ។ នេះរួមបញ្ចូលនូវយុទ្ធសាស្ត្រដែលចែងពីការវិវឌ្ឍន៍របស់ BFC ដើម្បីជួយគាំទ្រដល់ការសម្រេចចក្ខុវិស័យនេះ។

## វឌ្ឍនភាពដើម្បីឈានទៅបង្កើតនូវវិស័យមួយដែលមានស្ថិរភាព និងផ្តល់នូវភាពយុត្តិធម៌

នៅពេលដែល BFC ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០១ ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលកសាងប្រទេសឡើងវិញក្រោយជម្លោះដែលអូសបន្លាយក្នុងរយៈពេលមួយដ៏វែង។ ប្រទេសនេះទើបតែចាប់ផ្តើមរៀបចំច្បាប់ស្តីពីការងាររបស់ខ្លួន ហើយកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាង សហរដ្ឋអាមេរិក និងប្រទេសកម្ពុជា គឺជាជំហានដ៏សំខាន់មួយសម្រាប់ការចាប់ផ្តើមដំណើរការឧស្សាហូបនីកម្មរបស់ប្រទេសនេះ។ កិច្ចព្រមព្រៀងនេះនាំមកនូវការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនរោងចក្រ ការងារ កំណើននៃការនាំចេញ និងការរីកចម្រើននៃការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរបស់ប្រទេសនេះ។ ក្នុងពេលជាមួយគ្នានេះកម្មករនិយោជិត និងនិយោជកមានចំណេះដឹងតិចតួចពីច្បាប់ស្តីពីការងារ ហើយពុំមានការធ្វើអធិការកិច្ចឲ្យបានគ្រប់គ្រាន់ឡើយ រីឯកិច្ចសន្ទនាសង្គមក៏នៅខ្វះចន្លោះ ហើយនៅក្នុងវិស័យនេះមានការបំពានច្បាប់ស្តីពីការងារ ការធ្វើកូដកម្មភ្លាមៗដោយពុំមានការគ្រោងទុកជាមុន និងស្ថានភាពដែលកើតឡើងដោយគេពុំអាចព្យាករណ៍ទុកជាមុនជាច្រើនទៀត។ ទោះជាយ៉ាងណាក៏ដោយ មានការផ្លាស់ប្តូរយ៉ាងច្រើនចាប់តាំងពីពេលនោះមក។

ខណៈពេលដែលមានការទទួលស្គាល់ថាវិស័យនេះនៅនៅពុំទាន់មានការអនុលោមតាមច្បាប់ការងារឲ្យបានល្អប្រសើរនៅឡើយ ជាមួយគ្នានេះដែរកិច្ចខិតខំប្រឹងប្រែងជាច្រើនក៏ត្រូវបានគិតគូ។ ឧទាហរណ៍ ជាមួយនឹងវត្តមានរយៈពេល ១៧ ឆ្នាំរបស់កម្មវិធីនេះនៅក្នុងប្រទេស តួអង្គពាក់ព័ន្ធនានាយល់ស្របថា BFC (i) បំពេញ តួនាទីយ៉ាងសំខាន់ក្នុងការធានានិរន្តរភាពកំណើន ជារួមនៃឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា, (ii) រួមចំណែកកែលម្អជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋប្រមាណ ២,៤ លាននាក់ដែលពឹងអាស្រ័យលើចំណូលពីឧស្សាហកម្មកាត់ដេរ, (iii) បានបង្កើតនូវមូលដ្ឋានដើម្បីឲ្យមានការប្រកួតប្រជែងស្មើភាពគ្នារវាងរោងចក្រកាត់ដេរនៅកម្ពុជាដែលផលិតសម្រាប់នាំចេញ (iv) មានឥទ្ធិពលលើរបៀបធ្វើការងារតាមរយៈការប្រើប្រាស់ទិន្នន័យរបស់រោងចក្រក្នុងការជំរុញឲ្យមានការកែលម្អ និងក្លាយជាសមាសភាគដ៏សំខាន់មួយក្នុងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់អ្នកបញ្ជាទិញអន្តរជាតិ, (v) ធ្វើឲ្យរោងចក្រកាត់ដេរនៅកម្ពុជាមានសុវត្ថិភាពជាងមុន, (vi)រួមចំណែកដល់ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យនេះ និង (vii) ធានាថាកម្មករនិយោជិតទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្នែកកិច្ចគាំពារសង្គមក្នុងកម្រិតមួយដែលត្រឹមត្រូវ។

លើសពីនេះសមិទ្ធផល និងគំនិតផ្តួចផ្តើមសំខាន់ៗផ្សេងទៀត និងគំនិតផ្តួចផ្តើមសម្រាប់គាំទ្រឲ្យវិស័យនេះមានស្ថិរភាព មានភាពប្រកួតប្រជែង និងផ្តល់នូវភាពយុត្តិធម៌ក៏ត្រូវបានធ្វើឡើងផងដែរមានដូចជា៖

- ដំណើរការកំណត់ប្រាក់ឈ្នួលអប្បបរមាដែលក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានលើកជាអនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាលជារៀងរាល់ឆ្នាំស្តីពីការកែសម្រួលប្រាក់ឈ្នួលអប្បបរមា។ ការកំណត់ប្រាក់ឈ្នួលអប្បបរមាត្រូវអនុវត្តតាមលក្ខខណ្ឌវិនិច្ឆ័យដែលមានចែងនៅក្នុងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។
- ការប្តេជ្ញាចិត្តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើនប្រសិទ្ធភាពនៃមុខងារអធិការកិច្ចរបស់ខ្លួនដែលកន្លងមកនាំមកនូវការកែសម្រួលបញ្ជីត្រួតពិនិត្រមសីលធម៌ក៏ដូចជាការប្រើប្រាស់វិធីសាស្ត្រលើកកម្ពស់ភាពអនុលោមតាមច្បាប់ការងារជាយុទ្ធសាស្ត្រសម្រាប់អនុវត្តផែនការអធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង។
- ការប្តេជ្ញាចិត្តរបស់ក្រសួងពាណិជ្ជកម្មដើម្បីឲ្យមានលក្ខខណ្ឌការងារល្អដែលជាផ្នែកមួយដ៏សំខាន់ក្នុងគោលនយោបាយពាណិជ្ជកម្មក្នុងវិស័យកាត់ដេរ និងវិស័យនាំចេញសំខាន់ៗផ្សេងទៀត។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលត្រូវបាននិយោជកក៏ដូចជាកម្មករនិយោជិត  និងសហជីពចាត់ទុកថាជាអ្នកទុកជាអ្នកដោះស្រាយវិវាទការងាររួមដែលមានអព្យាក្រិតភាព និងយុត្តិធម៌ត្រឹមត្រូវសម្រាប់ជម្លោះពាក់ពាក់ព័ន្ធនឹងការងារ   ហើយដែលសេចក្តីបង្គាប់ជារឿយៗបានទទួលការគោរពពីភាគីទាំងនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល  និងមូលនិធិអាជ្ញាកណ្តាល គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់អ្នកបញ្ជាទិញ ដូច្នេះស្ថាប័នទាំងពីរនេះបំពេញតួនាទីយ៉ាងសំខាន់ដើម្បីបង្កើនទំនុកចិត្តរបស់បណ្តាក្រុមហ៊ុនរោងចក្រនានាក្នុងប្រទេសកម្ពុជាដែលត្រូវបានចាត់ទុកជាប្រទេសគោលដៅសម្រាប់ការដាក់ការបញ្ជាទិញ។
- ចំនួនកាន់តែច្រើនជាងមុនដែលមានគណៈកម្មកម្មការទ្វេភាគីជាអ្នកទទួលខុសត្រូវក្នុងការកែលម្អបញ្ហាដែលកើតមាននៅកន្លែងធ្វើការ។ បើទោះបីជាគណៈកម្មការទ្វេភាគីខ្លះ មិនអាចបំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព ប៉ុន្តែជារឿយៗ គណៈកម្មការទាំងនេះ  គឺជាយន្តការដំបូងសម្រាប់កិច្ចសន្ទនាសង្គមដែលមានការរៀបចំត្រឹមត្រូវដែលជួយកែលម្អលក្ខខណ្ឌការងារនៅក្នុងរោងចក្រក៏ដូចជាការប្រាស្រ័យទាក់ទងគ្នារវាងតំណាងកម្មករ  និងអ្នកគ្រប់គ្រងរោងចក្រ។
- ការបង្ហាញជាសាធារណៈអំពីលទ្ធផលនៃការគោរពច្បាប់នៅតាមរោងចក្រនីមួយៗជុំវិញបញ្ហាការអនុវត្តច្បាប់សំខាន់ៗក៏ដូចជារបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃកម្រិតភាពអនុលោមតាមច្បាប់របស់ឧស្សាហកម្ម គឺផ្អែកទៅតាមទិន្នន័យការត្រួតពិនិត្យលក្ខខណ្ឌការងាររបស់ BFC។
- ការសហការរវាងក្រសួងពាណិជ្ជកម្ម  ក្រសួងការងារ  និងបណ្តុះបណ្តាលវិជ្ជាជីវៈ  និង BFC ដើម្បីឆ្លើយតបចំពោះបញ្ហាដែលមិនអាចអត់ឱនឲ្យបាននៅក្នុងរោងចក្រក៏ដូចជារោងចក្រដែលមានភាពអនុលោមតាមច្បាប់ទាប ដើម្បីឲ្យពួកគេធ្វើការកែលម្អការ។
- ការបន្តការចរចាកាលពីពេលថ្មីៗនេះរវាង GMAC និងតំណាងសហជីពអំពីអនុសញ្ញារួមដំបូង ដែលមិនធ្លាប់មានសម្រាប់វិស័យកាត់ដេរ  និងសម្លៀកបំពាក់ទាំងមូល។
- គំនិតផ្តួចផ្តើមសហការគ្នារបស់ក្រុមហ៊ុនអ្នកបញ្ជាទិញធំៗជាង ២០ ដែលភាគច្រើននៅអឺរ៉ុបដើម្បីគាំទ្រដល់ការផ្តល់ប្រាក់ឈ្នួលសមរម្យ និងការចរចាជាសមូហភាពដែលមានឈ្មោះថា ACT។ ប្រទេសកម្ពុជា  គឺជាប្រទេសមួយក្នុងចំណោមប្រទេសចំនួនបួនដែល ACT កំពុងធ្វើការងារជាមួយនឹងរោងចក្រអ្នកផលិត  សហជីព និងនិយោជកដើម្បីប្រើប្រាស់អនុសញ្ញារួមសម្រាប់បញ្ចូលភាសាជុំវិញប្រាក់ឈ្នួលសមរម្យដែលបន្ទាប់ពីមានការឯកភាពគ្នា ហើយវិស័យកាត់ដេរនៅកម្ពុជានឹងទទួលបានការសន្យាបញ្ជាទិញពីក្រុមហ៊ុនអ្នកបញ្ជាទិញទាំងនេះក្នុងបរិមាណ  និងតម្លៃមួយជាក់លាក់។ ខណៈពេលដែលការចរចា

ឲ្យរោងចក្រកាន់តែអាចព្យាករណ៍ដឹងជាមុនអំពីបរិមាណ និងតម្លៃនៃការបញ្ជាទិញ។ នៅកំពុងបន្តធ្វើកិច្ចព្រមព្រៀង ដូច្នេះកិច្ចការនេះទំនងជាមានផលវិជ្ជមានទៅដល់ការបញ្ជាទិញរបស់ក្រុមហ៊ុនអ្នកបញ្ជាទិញនានា គឺកាន់តែមានភាពល្អប្រសើរជាងមុន និងធ្វើឲ្យរោងចក្រកាន់តែអាចព្យាករណ៍ដឹងជាមុនអំពីបរិមាណ និងតម្លៃនៃការបញ្ជាទិញ។

- យុទ្ធសាស្ត្រជាតិសំខាន់ៗត្រូវបានបញ្ចូលអាទិភាពពាក់ព័ន្ធនឹងការពង្រឹងអភិបាលកិច្ចទីផ្សារការងារជាពិសេសសម្រាប់វិស័យកាត់ដេរ។ ឧទាហរណ៍ ដូចជាគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ក៏ដូចជាយុទ្ធសាស្ត្រចតុកោណដែលឯកសារទាំងពីរនេះសុទ្ធតែបានបញ្ចូលអាទិភាពជាច្រើនពាក់ព័ន្ធនឹងការធ្វើឲ្យទំនាក់ទំនងឧស្សាហកម្មមានស្ថេរភាព និងមានភាពចាស់ទុំក៏ដូចជាពង្រឹងយន្តការអធិការកិច្ច និងយន្តការអនុវត្តច្បាប់។
- សេចក្ដីព្រាងយុទ្ធសាស្ត្រសម្រាប់វិស័យនេះដែលក្នុងនោះលក្ខខណ្ឌការងារល្អប្រសើរ គឺជា ចំណុចស្នូល។

សម្រាប់ដំណាក់កាលយុទ្ធសាស្ត្រថ្មីរបស់BFC គឺតួអង្គពាក់ព័ន្ធក្នុងឧស្សាហកម្ម និងតួអង្គពាក់ព័ន្ធត្រីភាគីសុទ្ធតែបានដឹងថាមានការសម្រេចបាននូវវឌ្ឍនភាពសំខាន់ៗឆ្ពោះទៅកសាងវិស័យមួយដែលមានភាពរឹងមាំ និងយុត្តិធម៌ជាមួយនឹងការលើកកម្ពស់សុវត្ថិភាព សុខភាព និងផលិតភាពនៅកន្លែងធ្វើការ។ តួអង្គពាក់ព័ន្ធរបស់ឧស្សាហកម្មនេះ និងតួអង្គពាក់ព័ន្ធត្រីភាគីក៏បានដឹងផងដែរថានៅមានការងារជាច្រើនផ្សេងទៀតដែលចាំបាច់ត្រូវធ្វើដើម្បីធានាយ៉ាងណាឲ្យវឌ្ឍនភាពដែលសម្រេចបានកន្លងមកនៅតែបន្តមានទៀត និងចុងក្រោយធ្វើឲ្យវិស័យកាត់ដេរនេះប្រែក្លាយជាឧស្សាហកម្មដែលមានភាពប្រកួតប្រជែង និងមានការគោរពសិទ្ធិកម្មករ និយោជក និងតំណាងកម្មករអាចដោះស្រាយបញ្ហាតាមរយៈកិច្ចសន្ទនាសង្គមដែលមានភាពចាស់ទុំ ហើយស្ថាប័ននានាក៏អាចធ្វើអន្តរាគមន៍ ផ្ដល់ដំបូន្មាន និងជម្រុញការអនុវត្តច្បាប់ក្នុងករណីដែលចាំបាច់ និងដែលក្រុមហ៊ុន អ្នកបញ្ជាទិញផ្ដល់ការគាំទ្រដល់ការកែលម្អជាប្រចាំតាមរយៈការដាក់ការបញ្ជាទិញជាប់ឋិតថេរ និងការផ្ដល់តម្លៃសមរម្យសម្រាប់ការបញ្ជាទិញរបស់ខ្លួន។

នៅក្នុងកិច្ចពិគ្រោះយោបល់ទាំងនេះក៏មានការស្នើសុំមតិត្រលប់អំពីអាទិភាពសម្រាប់យុទ្ធសាស្ត្របួនឆ្នាំបន្ទាប់របស់ BFC ហើយអាទិភាពផ្នែកប្រតិបត្តិការទាំងនេះនឹងត្រូវលើកយកមក ធ្វើការពិភាក្សាក្នុងផ្នែកបន្ទាប់នៃឯកសារនេះ។ ទោះជាយ៉ាងណាក៏ដោយយើងបានយល់យ៉ាងច្បាស់ថា តួអង្គពាក់ព័ន្ធ និងដៃគូនានារំពឹងថា BFC នឹងចាប់ផ្ដើមដំណើរការរួមគ្នាជាមួយនឹងពួកគេដើម្បីកំណត់ពីអ្វីដែលចាំបាច់ត្រូវធ្វើ គឺសំដៅសម្រេចចក្ខុវិស័យរយៈពេលវែងនៃឧស្សាហកម្មនេះ ដូចជា ការដាក់ចេញនូវតួនាទី និងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធនីមួយៗរួមទាំង BFC ផងដើម្បីសម្រេចនូវលទ្ធផលដែលបានគ្រោងទុកក៏ដូចជាការដាក់ចេញនូវសូចនាករដែលមានភាពរឹងមាំសម្រាប់វាស់វែងវឌ្ឍនភាពដែលសម្រេចបាន។

## អាទិភាព និងចក្ខុវិស័យរបស់តួអង្គពាក់ព័ន្ធសម្រាប់ដំណាក់កាលយុទ្ធសាស្ត្រថ្មី

ជាមួយនឹងទិសដៅជាយុទ្ធសាស្ត្ររួមដែលរយៈពេលវែងនេះដៃគូនានាក៏ទទួលស្គាល់ពីតួនាទីដែល BFC គួរបន្តបំពេញនៅកម្រិតរោងចក្រដោយផ្ដោតការយកចិត្តទុកដាក់លើរោងចក្រទាំងឡាយណាដែលបំពេញការងារក្រោមមធ្យមភាគក៏ដូចជាការបង្កើតគំរូភាពបង្ហាញពីភាពដឹកនាំរបស់រោងចក្រដែលអាចលើកទឹកចិត្តឲ្យរោងចក្រដែលអាចផ្ដល់ការលើកទឹកចិត្តដល់រោងចក្រដែលនៅសេសសល់នៅក្នុងឧស្សាហកម្មនេះ និងប្រើប្រាស់គំរូទាំងនេះដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីអ្វីដែលដំណើរការទៅប្រកបដោយប្រសិទ្ធភាព។ លើសពីនេះនឹងផ្សាភ្ជាប់ទំនាក់ទំនងជាមួយនឹងការបង្កើតចក្ខុវិស័យថ្មីសម្រាប់ឧស្សាហកម្មដូចដែលបានរៀបរាប់ក្នុងផ្នែកមុន ហើយដៃគូនានាក៏បានរំលេចនូវអាទិភាពមួយចំនួនសម្រាប់រយៈពេលបួនឆ្នាំខាងមុខដូចខាងក្រោម៖



- ពង្រឹង និងធ្វើឲ្យទំនាក់ទំនង និងភាពជាដៃគូជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកាន់តែមានភាពស៊ីជម្រៅដើម្បីកសាងសមត្ថភាព ជំនាញ និងភាពអាចជឿទុកចិត្ត និងធានាសង្គតិភាពនៃការបកស្រាយច្បាប់ស្តីពីការងារ លិខិតបទដ្ឋានគតិយុត្ត និងអនុសញ្ញានានា
- រួមគ្នាជាមួយនឹងដៃគូនានាបង្កើតនូវគំរូដែលកាន់តែមានភាពរឹងមាំជាងមុនសម្រាប់ពិនិត្យតាមដានលក្ខខណ្ឌការងារនៅតាមរោងចក្រមៅការបន្តក្នុងឧស្សាហកម្មនេះ និងរោងចក្រផលិតដែលនៅកម្រិតទីពីរក្នុងឧស្សាហកម្មនេះ។
- កំណត់ និងផ្សព្វផ្សាយពីករណីសិក្សាអំពីការអនុវត្តល្អៗ ដើម្បីបង្ហាញពីតម្លៃ ឬក៏អត្ថប្រយោជន៍នៃបរិមាណផលិកម្មដែលបានអនុលោមតាមច្បាប់ប្រកបដោយគុណភាព និងប្រើប្រាស់គោលវិធីបែបសហគ្រិនភាពបន្ថែមទៀតដើម្បីធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ និងធ្វើការកៀរគរធនធាននានា។
- ពង្រីក និងបង្កើតភាពជាដៃគូថ្មីៗជាមួយនឹងអ្នកជំនាញខាងផ្នែកសុវត្ថភាព និងសុខភាពការងារ ការគ្រប់គ្រងបរិស្ថាន និងសំណល់ ភាពច្នៃប្រឌិតបច្ចេកវិទ្យាថ្មីៗ និងផ្នែកផ្សេងទៀតដែលមានសារៈសំខាន់សម្រាប់ធានានិរន្តរភាព និងផលិតភាពរបស់រោងចក្រ។
- បន្តគំនិតផ្តួចផ្តើម និងភាពជាដៃគូនានា ជុំវិញការលុបបំបាត់ពលកម្មកុមារ សុខភាពបន្តពូជរបស់ស្ត្រី ការបៀតបៀនផ្លូវភេទ និងរើសអើងនៅកន្លែងធ្វើការឲ្យកាន់តែមានភាពស៊ីជម្រៅ បន្ថែមទៀត។
- បន្តបង្កើនការយល់ដឹង និងផ្តល់ការបណ្តុះបណ្តាលដល់សហជីព និងតំណាងរបស់ពួកគេនៅកន្លែងធ្វើការឲ្យកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀតអំពីច្បាប់ស្តីពីការងារព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងអនុសញ្ញាពាក់ព័ន្ធតាមរយៈការរៀបចំឯកសារបណ្តុះបណ្តាល និង ឯកសារពាក់ព័ន្ធនានាឲ្យកាន់តែសមស្របតាមស្ថានភាពនៅកន្លែងធ្វើការនីមួយៗហើយកិច្ចការនេះនឹងកាន់តែឆ្លុះបញ្ចាំងពីកម្រិតនៃការអប់រំ និងកម្រិតនៃអក្ខរកម្មរបស់កម្មករគាត់ដែរ។

- ពង្រីកការងារដែលមានស្រាប់ជាមួយនឹងក្រុមរោងចក្រផលិតដើម្បីបង្កើន និងជម្រុញដល់ការអនុវត្តល្អក្នុងក្រុមរោងចក្រផលិតទាំងនេះ។
- ប្រើប្រាស់កិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជុំវិញការរៀបចំយុទ្ធសាស្ត្រសម្រាប់វិស័យកាត់ដេរ  ដើម្បីជំរុញឲ្យគោលនយោបាយនានារបស់រដ្ឋាភិបាលមានភាពស៊ីសង្វាក់គ្នា និងកសាងភាពជាដៃគូជាមួយនឹងតួអង្គពាក់ព័ន្ធនានាដើម្បីលើកកម្ពស់មុខមាត់របស់ឧស្សាហកម្មនេះ។
- បន្តអនុវត្តសកម្មភាពរួមគ្នាជាមួយនឹងកម្មវិធីការងារកាន់តែប្រសើរ (Better Work) នៅកម្រិតសកល  រួមជាមួយនឹងសកម្មភាពដែល ILO កំពុងធ្វើក្នុងប្រទេសកម្ពុជាក្រោម ក្របខ័ណ្ឌនៃកម្មវិធីការងារសមរម្យប្រចាំប្រទេស (DWCP) សម្រាប់ឆ្នាំ ២០១៩-២០២៣ ដើម្បីធានាឲ្យមានការប្រើប្រាស់វិធីសាស្ត្ររួមបញ្ចូលគ្នាដើម្បីបង្កើតការងារប្រកបដោយគុណភាព  ជាពិសេសសម្រាប់ស្ត្រីជាមួយនឹងការបង្កើតបរិយាកាសទំនាក់ទំនងវិជ្ជាជីវៈនិងលក្ខខណ្ឌការងារដែលពាក់ព័ន្ធឲ្យកាន់តែប្រសើរជាងមុន។

អាទិភាពទាំងនេះ ត្រូវបានបង្ហាញលជាមួយនឹងលទ្ធផលលម្អិតជាច្រើនបន្ថែមទៀត និងសកម្មភាពផ្សេងទៀតនៅក្នុងផ្នែកបន្ទាប់។



## យុទ្ធសាស្ត្រសំខាន់ៗ ២០១៩ - ២០២២

### ១. ពន្លឿនការកែលម្អលក្ខខណ្ឌការងារតាមបណ្ដារោងចក្រនានាប្រកបដោយចីរភាព

◆ បន្តពិនិត្យ តាមដាន និងរាយការណ៍ជាសាធារណៈអំពីកម្រិតនៃភាពអនុលោមតាមច្បាប់នៅតាមរោងចក្រកាត់ដេរសម្រាប់នាំចេញ និងកសាងសមត្ថភាពរបស់រោងចក្រ និងកម្មករដើម្បីឲ្យពួកគេអាចធ្វើការកែលម្អលក្ខខណ្ឌការងារដោយប្រើប្រាស់វិធីសាស្ត្រជាប្រព័ន្ធ និងយន្តការនៃកិច្ចសន្ទនាសង្គមនៅកម្រិតរោងចក្រ។

◆ សម្របសម្រួលការរៀបចំវិធីសាស្ត្រធានាឲ្យមានការអនុលោមតាមច្បាប់ជាយុទ្ធសាស្ត្រក្រោមភាពជាម្ចាស់របស់ឧស្សាហកម្មនេះផ្ទាល់សម្រាប់រោងចក្រម៉ៅកាបន្ត និងរោងចក្រដែលគោរពតាមច្បាប់ក្នុងកម្រិតមួយទាប។

◆ កំណត់ និងផ្ដល់ការគាំទ្រដល់រោងចក្រមួយចំនួនដើម្បីឲ្យរោងចក្រទាំងនោះក្លាយទៅជារោងចក្រនាំមុខគេខាងភាពអនុលោមតាមច្បាប់ក្នុងឧស្សាហកម្មនេះ និងលើកទឹកចិត្ត ឲ្យរោងចក្រផ្សេងទៀតយកគំរូតាម។

◆ ពង្រីកភាពជាដៃគូជាមួយនឹងអង្គការស្ថាប័នផ្សេងទៀត ដើម្បីគាំទ្រដល់រោងចក្រជុំវិញនៃអាទិភាពពាក់ព័ន្ធនឹងផ្នែកសុខភាព និង សុវត្ថិភាពការងារ បញ្ហាយេនឌ័រ និងបច្ចេកវិទ្យាថ្មីៗ។ល។

◆ បន្តបង្កើនគុណភាព និងសង្គតិភាពរបស់ BFC ជុំវិញសេវាសំខាន់ៗនៅកម្រិតរោងចក្រ ដើម្បីធានា យ៉ាងណាឲ្យ BFC នៅតែបន្តបំពេញទៅតាមស្តង់ដារគុណភាពខ្ពស់បំផុត។

### ២. សម្របសម្រួលការរៀបចំចក្ខុវិស័យដែលផ្ដោតលើការធានាភាពអនុលោមតាមច្បាប់ក្នុងឧស្សាហកម្មនេះ

- ចាប់ផ្ដើមសម្របសម្រួលដំណើរការដើម្បីឲ្យតួអង្គពាក់ព័ន្ធត្រីភាគី និងដៃគូរបស់ឧស្សាហកម្មក្នុងការរៀបចំនូវដំណើរការផ្លាស់ប្ដូរជាមួយនឹងលទ្ធផល និងសូចនាករដែលអាចវាស់វែងបានដើម្បីបង្កើតវប្បធម៌ការអនុលោមតាមច្បាការងារនៅក្នុងឧស្សាហកម្មនេះ។

◆ ពង្រឹងការសហការជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀតដើម្បីបង្កើនសមត្ថភាព ជំនាញ និងភាពជឿទុកចិត្តបានរបស់ក្រសួងដោយប្រើប្រាស់វិធីសាស្ត្រដើម្បីជំរុញឲ្យមានការគោរពតាមច្បាប់ជាយុទ្ធសាស្ត្រ និងគាំទ្រដល់ការសម្រេចចក្ខុវិស័យខាងលើ។

◆ ធ្វើការងារជាមួយនឹងចលនាសហជីពកម្ពុជាជុំវិញដំណើរការសម្រាប់ពង្រឹងជំនាញរបស់មេដឹកនាំសហជីពជាស្ត្រី និងបុរសនៅតាមរោងចក្រ និងតំណាងកម្មករជុំវិញការយល់ដឹង អំពីច្បាប់ស្ដីពីការងារ និងរបៀបចរចាប្រកបដោយប្រសិទ្ធភាពសម្រាប់គាំទ្រដល់ចក្ខុវិស័យខាងលើ។

◆ កំណត់ទៅលើផ្នែកដែលជាការសហការ និងការផ្ដល់ការបណ្តុះបណ្តាលរួមគ្នាជាមួយនឹង GMAC ដើម្បីគាំទ្រដល់រោងចក្រនានាក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនសម្រាប់គាំទ្រឲ្យមានភាពអនុលោមតាមច្បាប់ឲ្យល្អប្រសើរសម្រាប់គាំទ្រដល់ការសម្រេចចក្ខុវិស័យខាងលើ។

### ៣. បង្កើត និងពង្រីកភាពជាដៃគូជាមួយនឹងភាគីនានាដែលគាំទ្រដល់ការនាំមកនូវការផ្លាស់ប្ដូរជាវិជ្ជមានដល់ឧស្សាហកម្មនេះ

◆ គាំទ្រដល់យុទ្ធសាស្ត្រវិស័យកាត់ដេរតាមរយៈការកៀរគរដៃគូនានាឲ្យរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រនេះ។

◆ បង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមវិនិយោគ និងក្រុមរោងចក្រផលិតដើម្បីគាំទ្រឲ្យរោងចក្រនានាក្លាយជាអ្នកនាំមុខក្នុងឧស្សាហកម្មនេះ។

◆ ពង្រឹងភាពជាដៃគូជាមួយនឹងអ្នកបញ្ជាទិញ និងទាញប្រយោជន៍ពីភាពជាដៃគូនេះដើម្បីបន្តជំរុញលើកទឹកចិត្តឲ្យពួកគេចូលរួមដោះស្រាយ

បញ្ហាប្រឈម និងអនុវត្តគំនិតផ្តួចផ្តើមនានានៅនៅកម្រិតរោងចក្រ និងកម្រិតវិស័យ ក៏ដូចជាផ្តល់ឲ្យពួកគេនូវតួនាទីដែលពួកគេគួរបំពេញសម្រាប់ជំរុញឲ្យមានភាពអនុលោមតាមច្បាប់ប្រកបដោយចីរភាពក្នុងឧស្សាហកម្មមួយដែលពោរពេញដោយភាពប្រកួតប្រជែង និងយុត្តិធម៌។

- ◆ អនុវត្តគំនិតផ្តួចផ្តើមដែលមានស្រាប់ និងក្នុងករណីដែលអាចធ្វើទៅបាន គឺបង្កើតគំនិតផ្តួចផ្តើមថ្មីៗ សម្រាប់ឆ្លើយតបចំពោះបញ្ហាសមភាពយេនឌ័រក្នុងវិស័យនេះ ក៏ដូចជាពង្រឹងតួនាទីដែលកម្មករ និងតំណាងជាស្ត្រីអាចបំពេញបានក្នុងដំណើរការកែលម្អ និងក្នុងកិច្ចសន្ទនាសង្គម។

## ៨. វាស់វែង និងប្រើប្រាស់ទិន្នន័យ បទពិសោធន៍ និងចំណេះដឹងដើម្បីអប់រំផ្សព្វផ្សាយឲ្យមានការកែលម្អការអនុវត្តការងារសម្រាប់គាំទ្រដល់ការសម្រេចចក្ខុវិស័យសម្រាប់ឧស្សាហកម្មនេះ

- ◆ វិភាគទិន្នន័យ BFC ដើម្បីជួយរៀបចំគោលនយោបាយ និងការអនុវត្តនានានៅកម្រិតវិស័យ និងកម្រិតរោងចក្រ ដើម្បីគាំទ្រឲ្យមានភាពអនុលោមតាមច្បាប់ប្រកបដោយចីរភាពក្នុងឧស្សាហកម្មមួយដែលពោរពេញដោយភាពប្រកួតប្រជែង និងយុត្តិធម៌។
- ◆ ប្រើប្រាស់ទិន្នន័យដែលជាលទ្ធផលនៃការវាយតម្លៃលើលទ្ធផលរយៈពេលវែងនៃការងាររបស់ BFC ដើម្បីបង្ហាញពីរបៀបដែលកែលម្អលក្ខខណ្ឌការងារអាចមានឥទ្ធិពលជាវិជ្ជមានលើសុខុមាលភាពរបស់កម្មករ លទ្ធផលនៃអាជីវកម្មរបស់រោងចក្រ និងសហគមន៍។
- ◆ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រអប់រំផ្សព្វផ្សាយជាសាធារណៈដើម្បីបង្ហាញពីជោគជ័យនៃកម្រិតវិស័យ និងកម្រិតរោងចក្រក្នុងគោលបំណងផ្សព្វផ្សាយពីភាពជោគជ័យទាំងនេះឲ្យកាន់តែទូលំទូលាយបន្ថែមទៀត។
- ◆ វាយតម្លៃ និងបង្កើតភាពជាដៃគូជាមួយនឹងវិស័យឯកជនដើម្បីគាំទ្រដល់ការប្រើប្រាស់វិធីសាស្ត្រអប់រំផ្សព្វផ្សាយថ្មីៗសម្រាប់ពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ ជាពិសេសដល់កម្មករនិយោជិត។

## ៩. ដឹកនាំ និងគ្រប់គ្រងកម្មវិធីដើម្បីឈានទៅសម្រេចឲ្យបាននូវការកែលម្អជាប់ជាប្រចាំ

- ◆ ធានាឲ្យមានការចូលរួមយ៉ាងសកម្មពីតួអង្គពាក់ព័ន្ធត្រីភាគីក្នុងការគ្រប់គ្រងកម្មវិធីនេះតាមរយៈគណៈកម្មការប្រឹក្សាគម្រោង។
- ◆ សម្របសម្រួលកិច្ចពិគ្រោះយោបល់ជុំវិញបញ្ហា និងអាទិភាពនៃកម្រិតវិស័យរវាងតួអង្គពាក់ព័ន្ធត្រីភាគី និងតួអង្គពាក់ព័ន្ធដទៃទៀត។
- ◆ ពង្រីកសមត្ថភាពគ្រប់គ្រងរបស់ BFC តាមរយៈការផ្តល់ការគាំទ្រ និងការអភិវឌ្ឍន៍សមត្ថភាព របស់ថ្នាក់ដឹកនាំក្នុងស្រុកដែលកំពុងបំពេញការងារនៅក្នុងកម្មវិធីនេះ។
- ◆ ជំរុញឲ្យមានវប្បធម៌សិក្សារៀនសូត្រក្នុងកម្មវិធីនេះដើម្បីឲ្យមានការកែលម្អជាប់ជាប្រចាំ។
- ◆ ធានាឱ្យមានការគ្រប់គ្រងហិរញ្ញវត្ថុដែលល្អប្រសើរប្រកបដោយប្រសិទ្ធភាពសម្រាប់ពង្រឹងនិរន្តរភាពផ្នែកហិរញ្ញវត្ថុ។

យុទ្ធសាស្ត្រសំខាន់ៗសម្រាប់រយៈពេលបួនឆ្នាំបន្ទាប់ត្រូវបានរៀបចំក្នុងទម្រង់ជាយុទ្ធសាស្ត្រប្រកបដោយមហិច្ឆតាខ្ពស់សម្រាប់ BFC និងដៃគូដែលត្រូវសម្រេចឱ្យបាន បើតាមការលើកឡើងរបស់តួអង្គពាក់ព័ន្ធនានា និងដើម្បីចាប់ផ្តើមដំណើរការឈានទៅសម្រេចចក្ខុវិស័យដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងឧស្សាហកម្មនេះ។ លក្ខខណ្ឌសំខាន់ៗដើម្បីឱ្យការអនុវត្តយុទ្ធសាស្ត្រ សំខាន់ៗទាំងនេះអាចធ្វើទៅបានប្រកបដោយជោគជ័យរួមមាន៖ (i) ការមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ (ii) ការប្តេជ្ញាចិត្តខ្ពស់ពីដៃគូទាំងអស់ ដែលផ្តល់លទ្ធភាពឱ្យ BFC អាចអនុវត្តការងាររបស់ខ្លួន ទាំងក្នុងរោងចក្រទាំងខាងក្រៅរោងចក្រ។

International
Labour
Organization

International
Finance
Corporation
WORLD BANK GROUP